**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

# <u>សេចក្ដីប្រកាសព័ត៌មាន</u>

## លទ្ធផលនៃកិច្ចប្រជុំរវាង រដ្ឋមន្ត្រីការបរទេសអាស៊ាន និងរដ្ឋមន្ត្រីការបរទេស និងអភិវឌ្ឍន៍នៃក្រុមប្រទេស G7 នៅទីក្រុងលីវើភូល ចក្រភពអង់គ្លេស

នៅថ្ងៃទី ១២ ខែធ្នូ ឆ្នាំ២០២១ តបតាមការអញ្ជើញរបស់លោកជំទាវ Elizabeth Truss រដ្ឋមន្ត្រីការបរទេស កំមិនវែល និងអភិវឌ្ឍន៍ និងជារដ្ឋមន្ត្រីកិច្ចការនារី និងសមភាព នៃចក្រភពអង់គ្លេស **ឯកឧត្ដម ប្រាក់ សុខុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិកម្ពុជា បានអញ្ជើញចូលរួមតាមប្រព័ន្ធវីដេអូក្នុងកិច្ចប្រជុំរវាងរដ្ឋមន្ត្រីការបរទេសអាស៊ាន និងរដ្ឋមន្ត្រីការបរទេស និងអភិវឌ្ឍន៍នៃក្រុមប្រទេស G7 ដែលបានរៀបចំឡើងនៅទីក្រុងលីវើភូល ចក្រភពអង់គ្លេស។

កិច្ចប្រជុំបានគូសបញ្ជាក់អំពីតម្រូវការដើម្បីជំរុញឱ្យកាន់ខ្លាំងថែមទៀតនូវចំណងទាក់ទង និងកិច្ចសហប្រតិបត្តិការរវាងអាស៊ាន និងក្រុមប្រទេស G7 សម្រាប់ផលប្រយោជន៍ទៅវិញទៅមករបស់ប្រជាជន សម្រាប់សន្តិភាព និងវិបុលភាពរួម។ កិច្ចសហប្រតិបត្តិការនៅក្នុងវិស័យសំខាន់ៗមួយចំនួនត្រូវបានលើកយកមកពិភាក្សា ជាពិសេស មធ្យោបាយដើម្បីពន្លឿនការទទួលបានវ៉ាក់សាំង និងការលើកកម្ពស់សន្តិសុខសុខភាពសកល បច្ចេកវិទ្យាឌីជីថល ការវិនិយោគលើវិស័យហេដ្ឋារចនាសម្ព័ន្ធ ការដោះស្រាយបញ្ហានានាដែលពាក់ព័ន្ធនឹងបម្រែបម្រួលអាកាសធាតុ ការពង្រីកពាណិជ្ជកម្ម សន្តិសុខតំបន់ រួមទាំងបញ្ហាលំហសមុទ្រផងដែរ។ ជាទូទៅ រដ្ឋមន្ត្រីការបរទេសអាស៊ានបានអំពាវនាវឱ្យលើកកម្ពស់កិច្ចសហប្រតិបត្តិការ និងភាពជាដៃគូ ស្របតាមទស្សនវិស័យអាស៊ាន ស្ដីពីឥណ្ឌូ-ប៉ាស៊ីហ្វិក (AOIP) និងវិស័យអាទិភាពចំនួនបួនដែលមានចែងនៅក្នុងនោះ។

**ឯកឧត្ដមឧបនាយករដ្ឋមន្ត្រី** បានគូសបញ្ជាក់ពីសារសំខាន់នៃស្មារតីអាស៊ានក្នុងនាមជាគ្រួសាររួបរួមគ្នាដែលមានសមាជិកចំនួនដប់ប្រទេស ដែលស្មារតីនេះ គឺជាកត្តាជំរុញនៃមូលបទរបស់ប្រធានអាស៊ានឆ្នាំ ២០២២ «អាស៊ានរួមគ្នាធ្វើ៖ ដោះស្រាយបញ្ហាប្រឈមទាំងអស់គ្នា»។ **ឯកឧត្ដមឧបនាយករដ្ឋមន្ត្រី** បានលើកឡើងអំពីចំនុចអាទិភាពសំខាន់ៗរបស់កម្ពុជា និងឯកសារសមិទ្ធផលសម្រាប់ដំណើរការកសាងសហគមន៍អាស៊ាន នៅឆ្នាំក្រោយ ព្រមទាំងការយកចិត្តទុកដាក់បន្ទាន់ចំពោះការបង្កើតឱ្យមានដំណើរការប្រកបដោយសន្តិវិធីក្នុងការដោះស្រាយវិបត្តិនៅមីយ៉ាន់ម៉ា ដែល

អាសយដ្ឋាន: លេខ ៣ វិថី **សម្ដេច ហ៊ុន សែន**
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល : mfaic@mfaic.gov.kh

គួរតែជាកម្មសិទ្ធិរបស់មីយ៉ាន់ម៉ា និងដឹកនាំដោយមីយ៉ាន់ម៉ា។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានជម្រាបជូនអង្គប្រជុំអំពីគម្រោងទៅបំពេញទស្សនកិច្ចនៅប្រទេសមីយ៉ាន់ម៉ារបស់ សម្តេចតេជោនាយករដ្ឋមន្ត្រី ហ៊ុន សែន នៅដើមខែមករា ដើម្បីត្រួសត្រាយផ្លូវឆ្ពោះទៅរកវឌ្ឍនភាពនៃកិច្ចព្រមព្រៀងជាឯកច្ឆន្ទ៥ចំណុចរបស់អាស៊ាន។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានគូសបញ្ជាក់ថា របៀបវារៈកំពូលរបស់កម្ពុជា គឺបង្កើតបរិយាកាសអំណោយផលសម្រាប់កិច្ចសន្ទនាប្រកបដោយបរិយាប័ន្ន និងទំនុកចិត្តផ្នែកនយោបាយ ក្នុងចំណោមភាគីពាក់ព័ន្ធទាំងអស់ ដើម្បីសម្រេចបាននូវមូលដ្ឋានគ្រឹះរួមគ្នាមួយ លើដំណើរការឆ្ពោះទៅរកការបញ្ចប់អំពើហិង្សា និងទទួលបាននូវការឯកភាពគ្នាក្នុងចំណោមភាគីពាក់ព័ន្ធ សម្រាប់ការពន្លឿនការផ្តល់ជំនួយមនុស្សធម៌ទៅដល់អ្នកដែលខ្វះខាតបំផុត។

អំពីការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានកត់សម្គាល់ថា អាស៊ាន និងក្រុមប្រទេសG7 រួមគ្នា បានបង្កើតនូវសន្ទុះល្អលើគំនិតផ្តួចផ្តើមការតភ្ជាប់ជាច្រើន។ ឧទាហរណ៍មួយក្នុងចំណោមនោះគឺ ការបិទបញ្ចប់ការចរចារលើកិច្ចព្រមព្រៀងដឹកជញ្ជូនផ្លូវអាកាសគ្រប់ជ្រុងជ្រោយ អាស៊ាន-សហភាពអឺរ៉ុប។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានសង្កត់ធ្ងន់ថា គម្រោងទាំងឡាយដែល អាស៊ានកំពុងធ្វើការជាមួយដៃគូសន្ទនាមួយចំនួនមកពីក្រុមប្រទេស G7 គឺជាសុទ្ធតែគម្រោងវិស័យដែលអាចធ្វើសំយោគបានជាមួយនឹងផែនការមេស្តីពីការតភ្ជាប់អាស៊ាន (MPAC) ២០២៥។

សម្រាប់បញ្ហាសន្តិសុខ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានរំលឹកឡើងវិញថា អាស៊ានជានិច្ចជាកាល គឺជាអង្គការតំបន់ដែលសម្លឹងមើលទៅខាងក្រៅ ហើយចាត់ទុកសណ្តាប់ធ្នាប់តំបន់ដែលយកអាស៊ានជាស្នូល ជាគោលគ្រឹះនៃសន្តិភាព សន្តិសុខ ស្ថិរភាព និងវិបុលភាពក្នុងតំបន់ និងពិភពលោក។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានអះអាងយ៉ាងម៉ឺងម៉ាត់ថា កម្ពុជាឈរលើគោលការណ៍រួបរួមសម្រាប់កិច្ចសហប្រតិបត្តិការ និងមិនមែនរួបរួមសម្រាប់ការប្រឈមមុខដាក់គ្នានោះទេ ស្របពេលជំរុញឱ្យមានតម្រូវការធ្វើការជាមួយគ្នាដើម្បីលើកកម្ពស់ការជឿជាក់និងការទុកចិត្តគ្នា និងពួតដៃគ្នាដោះស្រាយបញ្ហាប្រឈមផ្នែកសន្តិសុខរួមផ្សេងៗ ដែលការធ្វើដូចនេះ គ្រប់រដ្ឋទាំងអស់ មិនថាជារដ្ឋតូច ឬធំ អាចរស់នៅជាមួយគ្នា ជាមួយការប្រកួតប្រជែងដើម្បីភាពល្អប្រសើរទាំងអស់គ្នា៕

ថ្ងៃចន្ទ ៩កើត ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែធ្នូ ឆ្នាំ២០២១